00281836

E5/11/5

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០១/១៨-០៧-២០០៧-**អវតក/អជសដ**

**ដាក់តម្កល់ជូន:** អង្គជំនុំជម្រះសាលាដំបូង

**កាលបរិច្ឆេទដាក់ឯកសារ:** ១២/០២/២០០៩

**ភាគីអ្នកតម្កល់:** មេធាវីជនជាប់ចោទ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច**

**ភាសាដើម:** ភាសាបារាំង

**ប្រភេទឯកសារ:** **សាធារណៈ**

---

# ព័ត៌មានស្តីពីការព្រមព្រៀងលើអង្គហេតុដែលភាគី ក្រុមមេធាវីការពារក្តី និងសហព្រះរាជអាជ្ញា បានព្រមព្រៀងគ្នា

---

**<u>អ្នកដាក់តម្កល់:</u>**

**មេធាវីជនជាប់ចោទ កាំង ហ្គេកអ៊ាវ**

លោក **ការ សាវុធ**

លោក **François ROUX**

**ឯកសារបានទទួល**
**DOCUMENT RECEIVED/DOCUMENT REÇU**
**ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception):** 12 / FEB / 2009
**ម៉ោង (Time/Heure):** 15:30
**មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier:** [signature]

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 13 / 02 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**<u>តម្កល់ជូន:</u>**

**<u>ចៅក្រមអង្គជំនុំជម្រះសាលាដំបូង</u>**

លោកចៅក្រម **និល ណុន** ប្រធាន

លោកស្រីចៅក្រម **Silvia CARTWRIGHT**

លោកចៅក្រម **យ៉ា សុខន**

លោកចៅក្រម **Jean-Marc LAVERGNE**

លោកចៅក្រម **ធូ មណី**

**<u>សហព្រះរាជអាជ្ញា</u>**

លោកស្រី **ជា លាង**

លោក **Robert PETIT**

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>**

មេធាវី **គង់ ពិសី**

មេធាវី **ហុង គឹមសួន**

មេធាវី **យុង ផានិត**

មេធាវី **Silke STUDZINSKY**

មេធាវី **គីម ម៉េងឃី**

មេធាវី **ម៉ូច សុវណ្ណារី**

មេធាវី **Martine JACQUIN**

មេធាវី **Philippe CANNONE**

មេធាវី **ធី ស្រីនណា**

មេធាវី **Pierre Olivier SUR**

## គោរពជូនអង្គជំនុំជម្រះសាលាដំបូង

### I. សេចក្តីផ្តើម

១. តាមរយៈសេចក្តីណែនាំចុះថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ ២០០៩[1] អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ក្រុមមេធាវីការពារក្តី និងសហព្រះរាជអាជ្ញាឱ្យ "ដាក់ជូននូវរាល់ព័ត៌មានស្តីពីការព្រមព្រៀងលើអង្គហេតុដែលភាគីទាំងពីរបានព្រមព្រៀងគ្នា" ឱ្យបានយ៉ាងយូរត្រឹមថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៩។

២. ក្រុមមេធាវីការពារក្តីសូមដាក់ជូនអង្គជំនុំជម្រះសាលាដំបូង នូវព័ត៌មានដូចបានជម្រាបជូនខាងក្រោម ស្តីពីការព្រមព្រៀងលើអង្គហេតុដែលភាគីក្រុមមេធាវីការពារក្តី និងសហព្រះរាជអាជ្ញាបានព្រមព្រៀងគ្នា។

### II. ព័ត៌មានស្តីពីការព្រមព្រៀងលើអង្គហេតុដែលភាគី ក្រុមមេធាវីការពារក្តី និងសហព្រះរាជអាជ្ញា បានព្រមព្រៀងគ្នា

៣. ក្រុមមេធាវីការពារក្តីមានកិត្តិយសសូមជម្រាបអង្គជំនុំជម្រះសាលាដំបូងឱ្យបានជ្រាបថា ក្រុមមេធាវីការពារក្តីបានទទួលនូវឯកសារមួយច្បាប់កាលពីថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ ពីសហព្រះរាជអាជ្ញា ដែលមានចំណងជើងថា " ជំហររបស់ក្រុមមេធាវីការពារក្តី ចំពោះអង្គហេតុទាំងឡាយដែលបានលើកឡើងក្នុងដីកាដំណោះស្រាយ" ។

៤. សម្រាប់ក្រុមមេធាវីការពារក្តី ក៏ដូចជាសហព្រះរាជអាជ្ញា ឯកសារមួយនេះមានគោលដៅចុងក្រោយ សម្រាប់ផ្តល់ជាជំនួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការពិចារណាលើមូលដ្ឋាន

---

[1] សូមពិនិត្យមើល *សេចក្តីណែនាំដែលមានកម្មវត្ថុស្នើសុំព័ត៌មានបន្ថែមពីគូភាគី និងសហចៅក្រមស៊ើបអង្កេត ដើម្បីត្រៀមរៀបចំបើកសវនាការលើកដំបូង* របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ (E5/11)។

អង្គហេតុ ដែលគូភាគីទាំងឡាយបានខ្វែងគំនិតគ្នា ព្រមទាំងមានគោលដៅក្នុងការជួយជម្រុញដំណើរការកាត់សេចក្តីឱ្យប្រព្រឹត្តទៅបានឆាប់រហ័សផងដែរ ។

៥. បច្ចុប្បន្ននេះ ក្រុមមេធាវីការពារក្តីកំពុងធ្វើការត្រួតពិនិត្យលើសំណុំឯកសារមួយនេះ ដែលមានចំនួនសរុប ៧៥ ទំព័រ ជាភាសាខ្មែរ និង ៣៧ ទំព័រ ជាភាសាបារាំង ដោយចែកចេញជា ៣៥១ កថាខ័ណ្ឌ ។

៦. ក្រុមមេធាវីការពារក្តី អាចមានមូលដ្ឋានក្នុងការវាយតម្លៃលើអង្គហេតុទាំងឡាយដូចបានលើកឡើងក្នុងសំណុំឯកសារនោះបាន ដរាបណាខ្លួនបានធ្វើការពិនិត្យសិក្សាល្អិតល្អន់លើសំណុំឯកសារនោះចប់សព្វគ្រប់សិន។

៧. ហេតុដូចនេះ យោងលើធាតុផ្សំដូចបានលើកឡើងពីខាងដើម ក្រុមមេធាវីការពារក្តីមានកិត្តិយសសូមជម្រាបអង្គជំនុំជម្រះសាលាដំបូងឱ្យបានជ្រាបថា រហូតដល់ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៩ គូភាគីនៅពុំទាន់បានព្រមព្រៀងគ្នាលើអង្គហេតុនូវឡើយទេ ។

៨. ក្រុមមេធាវីការពារក្តី សូមធ្វើការធានាអះអាងថាខ្លួននឹងបញ្ចប់ការពិនិត្យសំណុំឯកសារក្នុងអំឡុងពេលដ៏ឆាប់ខាងមុខនេះ មុនការចាប់ផ្តើមបើកសវនាការលើអង្គសេចក្តី។

៩. ជាមួយគ្នានេះដែរ ក្រុមមេធាវីការពារក្តីសូមធ្វើការប្រកាសពីជំហររបស់ខ្លួនក្នុងការរក្សាសិទ្ធិមិនទទួលយកកិច្ចព្រមព្រៀងណាមួយ ប្រសិនណាបើកិច្ចព្រមព្រៀងនោះបង្ហាញឱ្យឃើញពីផលប៉ះពាល់ដល់អត្ថប្រយោជន៍ជនជាប់ចោទ **កាំង ហ្គេកអ៊ាវ**។

ES/11/5

[០០១/១៨-០៧-២០០៧-អវតក/អជសជ]

## សុំរក្សាសិទ្ធិកែប្រែគ្រប់យ៉ាង

| | | |
|---|---|---|
| សហមេធាវីទាំងពីរ<br>មេធាវី **កាវ សាវុត្ថ**<br>មេធាវី **François ROUX** | ភ្នំពេញ | |
| ឈ្មោះ | ទីកន្លែង | ហត្ថលេខា |